គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ៦៧ ចេញផ្សាយថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៣
No. 67 Released on February 6, 2023

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# បរធនបាលកិច្ចគ្រួសារ

## Family Trust



https://thumbor.forbes.com/thumbor/fit-in/900x510/https://www.forbes.com/advisor/wp-content/uploads/2022/07/960x0.jpeg-1-1.jpg

បរធនបាលកិច្ចគ្រួសារ គឺជាបរធនបាលកិច្ចមួយប្រភេទ ដែលត្រូវបានបង្កើតឡើងដោយបរធនបាលទាយកដែលជាធម្មតាជាមេគ្រួសារ ឬជាស្ថាបនិកអាជីវកម្មគ្រួសារ ដើម្បីផ្តល់អត្ថប្រយោជន៍ដល់សមាជិកគ្រួសារដ៏ទៃទៀត ដែលអាចទទួលផលប្រយោជន៍ពីអាជីវកម្មគ្រួសារ ឬទទួលផលប្រយោជន៍ពីការបែងចែកទ្រព្យសម្បត្តិគ្រួសារ ប៉ុន្តែមិនមានលទ្ធភាពមកចាត់ចែង ឬចូលរួមចាត់ចែងអាជីវកម្មគ្រួសារដោយផ្ទាល់ខ្លួនឬដោយសារមានលក្ខខណ្ឌកម្រិតផ្ទាល់ខ្លួនមួយចំនួន។

បរធនបាលកិច្ចប្រភេទនេះ អាចជួយធានា និងថែរក្សាផលប្រយោជន៍ពីអាជីវកម្មគ្រួសារ ឬពីទ្រព្យសម្បត្តិដែលគ្រួសារ បានកសាងឡើង ឬរក្សាទុក សម្រាប់ជាប្រយោជន៍ដល់សមាជិកគ្រួសារដទៃទៀត ប្រកបដោយនិរន្តភាព និងភាពត្រឹមត្រូវច្បាស់លាស់ នៅពេលដែលអវត្តមាននៃមេគ្រួសារនោះ។

បរធនបាលកិច្ចនេះមានបីភាគីសំខាន់ៗដូចជាបរធន-បាលទាយក(ម្ចាស់ទ្រព្យ), បរធនបាល(ជាបុគ្គល មានគុណវុឌ្ឍិ ចំណេះជំនាញវិជ្ជាជីវៈ បទពិសោធន៍ និងទទួលបានអាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ច) និងអត្ថគាហកៈ(ជាអ្នកទទួលផល-ប្រយោជន៍) និងត្រូវបានបង្កើតឡើងដោយកម្មវត្ថុស្របច្បាប់ និងមិនផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ។

Family Trust is a type of trust established by the trustor who is the head of a family or the founder of a family business to benefit other family members who may benefit from the family business or benefit from distribution of family assets but is inability to manage or take part in the family business on their own or due to certain personal situations.

This type of trust can help ensure and maintain the benefits of the family business or assets that the family has built or kept for the benefit of other family members in a sustainable and accurate manner in the absence of the head of the household.

There are three main key parties: the trustor (property owner), the trustee (a person with qualifications, knowledge, profession, experience and license from Trust Regulator) and the beneficiary (the person receives the benefits from the trust) and is established in accordance by laws and not contrary to public order.

**អត្ថបទ÷ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References:**

- ច្បាប់ស្តីពីបរធនបាលកិច្ច(២០១៩) និងបទប្បញ្ញត្តិពាក់ព័ន្ធ
- https://www.forbes.com/advisor/investing/financial-advisor/family-trust/

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

www.facebook.com/trustregulatorcambodia www.trustregulator.gov.kh (855) 23 237 888
អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh